សកម្មភាពរបស់គណៈមេធាវី

១. ទំនាក់ទំនងជាតិ និងអន្តរជាតិ

១.១ ទំនាក់ទំនងជាតិ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានស្នើដល់គណៈមេធាវីកម្ពុជា ជួយពង្រាយមេធាវីទៅតាមបណ្តាខេត្ត និងទីជនបទដើម្បីជួយការពារក្តីដល់ប្រជាពលរដ្ឋមានជីវភាពក្រីក្រមិនមានលទ្ធភាពជួលមេធាវីការពារ ឬមិនសូវយល់ពីបញ្ហាផ្លូវច្បាប់

សំណើរបស់សម្តេចតេជោ **ហ៊ុន សែន** បានធ្វើឡើងក្នុងពេលដែលសម្តេចអនុញ្ញាតឲ្យគណៈមេធាវីកម្ពុជា ដឹកនាំដោយលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីកម្ពុជាចូលជួបសម្តែងការគួរសមនាព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨នេះនៅវិមានសន្តិភាព។

ពាក់ព័ន្ធបញ្ហានេះ លោកមេធាវី **សួន វិសាល** បានគូសបញ្ជាក់ថា បច្ចុប្បន្នគណៈមេធាវីកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងយុត្តិធម៌ ដើម្បីជួយដល់ពលរដ្ឋក្រីក្រក៏ដូចជារៀបចំប្រព័ន្ធទិន្នន័យតាមដានករណីនីមួយៗផងដែរ។

នៅក្នុងជំនួបសម្តែងការគួរសមនាព្រឹកថ្ងៃនោះដែរ លោកមេធាវី **សួន វិសាល** ក៏បានជម្រាបសម្តេចតេជោ **ហ៊ុន សែន** ផងដែរអំពីសមិទ្ធផលការងារមួយចំនួនរបស់គណៈមេធាវីកម្ពុជា ដែលសម្រេចបាននាពេលកន្លងមក ក៏ដូចជាកំពុងធ្វើនាពេលបច្ចុប្បន្ន។

បើតាមលោក **អ៊ាង សុផល្លែត** ជំនួយការផ្ទាល់សម្តេចតេជោ បានប្រាប់ឲ្យដឹងថា នៅក្នុងជំនួបនេះ លោកមេធាវី **សួន វិសាល** បានជម្រាបសម្តេចតេជោថា គណៈមេធាវី បានធ្វើការកែទម្រង់យ៉ាងច្រើន ជាពិសេសលើវិស័យរដ្ឋបាល និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យអប់រំផងដែរ។ លោកបន្តថា គណៈមេធាវី បានធ្វើការកែទម្រង់ការងារ ដើម្បីធ្វើយ៉ាងណាឲ្យសមស្របទៅតាមបរិបទនៅកម្ពុជាផង និងអន្តរជាតិ នាពេលបច្ចុប្បន្នផង ហើយក៏បង្រៀនមេធាវីកម្ពុជា នូវបច្ចេកទេសការពារក្តីផង។

លោកមេធាវី **សួន វិសាល** ក៏បានគោរពរាយការណ៍ជូនសម្តេចតេជោ អំពីកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ ជាមួយគណៈមេធាវីអន្តរជាតិ ដែលបានដឹកនាំកិច្ចប្រជុំហើយនឹងរៀបចំកិច្ចប្រជុំសមាគមមេធាវីអាស៊ាន នៅកម្ពុជា នាពេលខាងមុខ។

សម្តេចតេជោ **ហ៊ុន សែន** បានស្វាគមន៍ចំពោះរបាយការណ៍ ដែលបានលើកឡើងដោយ លោកមេធាវី **សួន វិសាល** ហើយក៏បានណែនាំដល់គណៈមេធាវីកម្ពុជាថា រាល់ការកែទម្រង់ទាំងឡាយដែលគណៈមេធាវី នឹងធ្វើត្រូវធ្វើឲ្យស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាផង និងតាមនិយាមអន្តរជាតិផង។ សម្តេចតេជោ ក៏បានណែនាំឲ្យគណៈមេធាវីកម្ពុជាពិនិត្យមើលចំណុចមួយចំនួន ដែលលែងសមស្របទៅតាមកាលៈទេសៈ ព្រោះថាគណៈមេធាវី

បានបង្កើតឡើងតាំងពីឆ្នាំ១៩៩៥មក ដែលចំណុចមួយចំនួនមិនសមស្របតាមបរិបទសង្គមនាពេលបច្ចុប្បន្ននេះទេ។

ជំនួបពិភាក្សាការងាររវាងលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីជាមួយឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម អ៊ុក សាវុធ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

នាថ្ងៃច័ន្ទ ១១កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ នៅសាលាឧទ្ធរណ៍-មហាអយ្យការ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី បានជួបពិភាក្សាការងារជាមួយឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងឯកឧត្តម អ៊ុក សាវុធ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីជជែកពិភាក្សាការងារស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យយុត្តិធម៌។

របៀវារៈនៃជំនួបកិច្ចពិភាក្សាការងារនេះផ្តោតលើប្រធានបទស្តីពី៖

១) ការផ្តល់នីតិសម្បទាដល់មេធាវី

២) ការចាត់តាំងមេធាវីក្នុងរឿងជនក្រីក្រ

៣)កិច្ចសហប្រតិបត្តិការរបស់មេធាវី ក្នុងអំឡុងពេលដំណើរការរឿងក្តីនៅសាលាឧទ្ធរណ៍។

កិច្ចជំនួបពិភាក្សាការងារនេះបានលទ្ធផលដូចខាងក្រោម៖

១) ឯកឧត្តមប្រធានសាលាឧទ្ធរណ៍សម្រេចជាគោលការណ៍ គឺត្រូវដាក់តុមេធាវីឲ្យស្មើនឹងអគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

២) ឯកឧត្តមប្រធានសាលាឧទ្ធរណ៍បានណែនាំឲ្យចៅក្រម ទុកពេលវេលាសមរម្យសម្រាប់មេធាវីធ្វើសេចក្តីថ្លែងការណ៍ក្នុងការការពារកូនក្តីរបស់ខ្លួន នៅក្នុងពេលសវនាការ។

៣) សាលាឧទ្ធរណ៍នឹងផ្តល់ជូននូវការិយាល័យមួយសម្រាប់ប្រតិភូគណៈមេធាវីក្នុងការធ្វើការងាររបស់ខ្លួន។

៤) សាលាឧទ្ធរណ៍នឹងកោះហៅមេធាវីចាត់តាំង យ៉ាងហោចណាស់១ខែកន្លះមុនកាលបរិច្ឆេទ សវនាការ។ រាល់ការចាត់តាំងមេធាវីជាបន្ទាន់នឹងមិនឲ្យមានទៀតឡើយ។

១.២ ទំនាក់ទំនងអន្តរជាតិ

កិច្ចប្រជុំកំពូលរបស់ប្រធានគណៈមេធាវី នៃសមាគមច្បាប់ ប្រចាំតំបន់អាស៊ីនៅទីក្រុង Canberra ប្រទេសអូស្ត្រាលី

កាលពីថ្ងៃព្រហស្បតិ៍ ៦រោច និងថ្ងៃសុក្រ ៧រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី០២-០៣ ខែសីហា ឆ្នាំ២០១៨ លោកមេធាវី កុយ នាម អគ្គលេខាធិការរង លោកស្រីមេធាវី លឹម ច័ន្ទលីដា និងលោកស្រីមេធាវី សៅ កញ្ញា តំណាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមកិច្ចប្រជុំកំពូលរបស់ប្រធានគណៈមេធាវី នៃសមាគមច្បាប់ ប្រចាំតំបន់អាស៊ីនៅទីក្រុង Canberra ប្រទេសអូស្ត្រាលី ដែលមានសមាជិកចំនួន១៧ ប្រទេសចូលរួម ។

តំណាងកម្ពុជាបានចូលរួមកិច្ចប្រជុំសមាគមច្បាប់អាស៊ានៅប្រទេសសិង្ហបុរី

នាថ្ងៃទីពុធ ១៣កើត និងថ្ងៃព្រហស្បតិ៍ ១៤កើត ខែទុតិយាសាធ ឆ្នាំច សំរិទ្ធស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ ២០១៨ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គ-លេខាធិការនៃ គណៈមេធាវីបានចូលរួមក្នុងមហាសន្និបាតនៃ សមាគមច្បាប់អាស៊ានដែលបានប្រព្រឹត្តិទៅប្រទេសសិង្ហបុរី។

២. កិច្ចប្រជុំផ្ទៃក្នុង

ការប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារដែលបានដាក់ជូនសម្រាប់ការរៀបចំសន្និបាត

នាថ្ងៃព្រហស្បតិ៍ ១១កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី ក្រោមអធិបតីភាព លោកមេធាវី ព្រហ្ម វិចិត្ត អក្ខរា អគ្គលេខាធិការ បានដឹកនាំកិច្ចប្រជុំបុគ្គលិក ដើម្បីត្រួតពិនិត្យ និងរៀបចំការងារសម្រាប់ មហាសន្និបាតជ្រើសរើសប្រធានគណៈមេធាវី អាណត្តិទី១២ និងសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៩ កិច្ចប្រជុំនេះមានការចូលរួមបុគ្គលិកគ្រប់អង្គភាពទាំងអស់នៃគណៈមេធាវីរួមទាំង លោកអគ្គលេខាធិរងនៃគណៈមេធាវីផងដែរ។

កិច្ចប្រជុំបុគ្គលិកគណៈមេធាវីប្រចាំខែកញ្ញា

នាថ្ងៃច័ន្ទ ៨រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការ បានដឹកនាំកិច្ចប្រជុំបុគ្គលិក ដើម្បីត្រួតពិនិត្យការងារប្រចាំខែ និងលើកទិសដៅការងារសម្រាប់រៀបចំមហាសន្និបាតប្រចាំឆ្នាំ២០១៨ ។

កិច្ចប្រជុំបុគ្គលិកពិនិត្យការងារប្រចាំខែសីហា.

នាថ្ងៃព្រហស្បតិ៍ ៨រោច ខែបឋមាសាធ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈ-មេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការបានដឹកនាំកិច្ចប្រជុំបុគ្គលិក ដើម្បីត្រួតពិនិត្យការងារប្រចាំខែ និងលើកទិសដៅការងារប្រចាំខែថ្មី។ កិច្ចប្រជុំនេះការចូលរួមបុគ្គលិកគ្រប់អង្គភាពទាំងអស់នៃ គណៈមេធាវីរួមទាំងលោកអគ្គលេខាធិរងនៃ គណៈមេធាវីផងដែរ។

៣. កិច្ចប្រជុំគណៈកម្មការជំនាញ

៣.១ កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការការងារនៃគណៈមេធាវី

នាថ្ងៃសុក្រ ៩រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបកិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការការងារនៃគណៈមេធាវី។ លទ្ធផលដែលទទួលបានគឺគណៈកម្មការបានរៀបចំផែនការសម្រាប់ផ្សព្វផ្សាយច្បាប់ តាមរយៈវិទ្យុ ទូរទស្សន៍ និងព្រឹត្តិបត្រ ហើយគណៈកម្មការកិច្ចការការងារនឹងមានកិច្ចប្រជុំរៀងរាល់ ២ខែម្តង។



កិច្ចប្រជុំគណៈកម្មការកិច្ចការការងារប្រចាំខែសីហា

នៅថ្ងៃសុក្រ ១៤រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្ម-ការកិច្ចការការងារ នៃគណៈមេធាវី ជាលើកទី២។ លទ្ធផលដែលទទួលបានគឺ អង្គប្រជុំបាន សម្រេចជ្រើសរើសសមាជិកគណៈកម្មការបន្ថែម និងបានកំណត់ប្រធានបទសម្រាប់ផ្សព្វផ្សាយ ច្បាប់ តាមទូរស្សន៍នៅពេលខាងមុខ។

៣.២ កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការពាណិជ្ជកម្មនៃគណៈមេធាវី

កិច្ចប្រជុំគណៈកម្មការកិច្ចការពាណិជ្ជកម្មប្រចាំខែកក្កដា

នៅថ្ងៃសុក្រ ១កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការពាណិជ្ជកម្មនៃគណៈមេធាវី។ លទ្ធផលដែលទទួលបានគឺ គណៈកម្មការបានរៀបចំផែនការសម្រាប់ផ្សព្វផ្សាយច្បាប់ តាមរយៈវិទ្យុ ទូរទស្សន៍ និងព្រឹត្តបត្រ។

កិច្ចប្រជុំគណៈកម្មការកិច្ចការពាណិជ្ជកម្មប្រចាំខែសីហា

នៅថ្ងៃសុក្រ ៧រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការកិច្ចការពាណិជ្ជកម្មជាលើកទី២នៃគណៈមេធាវី។

នៅក្នុងដំណើរនៃកិច្ចប្រជុំគណៈកម្មការកិច្ចការពាណិជ្ជកម្មនេះ លោកស្រីមេធាវី យូ សួនទី ប្រធានគណៈកម្មការបានធ្វើបទបង្ហាញ អំពីប្រធានបទសម្រាប់ធ្វើការផ្សព្វផ្សាយ ច្បាប់នៅតាមទូរទស្សន៍នាពេលខាងមុខ។

៣.៣ កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការព្រហ្មទណ្ឌនៃគណៈមេធាវី

នៅថ្ងៃសុក្រ ៨កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការ ព្រហ្មទណ្ឌនៃគណៈមេធាវី។

លទ្ធផលដែលទទួលបានគឺ បានរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់សមាជិកគណៈកម្មការ កំណត់នូវប្រធានបទជាអត្ថិភាពសម្រាប់ធ្វើការសម្រាប់ផ្សព្វផ្សាយច្បាប់ តាមរយៈវិទ្យុ ទូរទស្សន៍ និងព្រឹត្តបត្រ។

៣.៤ កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី

ការប្រជុំគណៈកម្មការកិច្ចការរដ្ឋប្បវេណីប្រចាំខែកញ្ញា

នៅថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី។ សមាជិក-សមាជិកានៃគណៈកម្មការបានជជែកពិភាក្សាអំពីផែនការសម្រាប់ធ្វើវីដេអូផ្សព្វផ្សាយច្បាប់ និងពិភាក្សាមេរៀនស្តីពី សន្តតិកម្ម ដែលត្រូវលើយកមកធ្វើបទបង្ហាញតាមទូរទស្សន៍ ។

ការប្រជុំគណៈកម្មការកិច្ចការរដ្ឋប្បវេណីប្រចាំខែសីហា

នៅថ្ងៃអង្គារ ១១រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវីបានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកាគណៈកម្មការកិច្ចការរដ្ឋប្បវេណីជាលើកទី២នៃគណៈមេធាវី។

នៅក្នុងកិច្ចប្រជុំគណៈកម្មការកិច្ចការរដ្ឋប្បវេណីនេះ គឺបានជជែកពិភាក្សាគ្នាយ៉ាងលម្អិតអំពីខ្លឹមសារអត្ថបទដែលត្រូវផ្សាយនៅក្នុងព្រឹត្តិបត្រមេធាវីនាពេលខាងមុខ។ សមាជិកគណៈកម្មការនឹងចូលរួមផ្សព្វផ្សាយច្បាប់តាមវិទ្យុផងដែរ។

នៅថ្ងៃអង្គារ ២រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការ កិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី។ សមាជិក-សមាជិកានៃគណៈកម្មការបានជជែកពិភាក្សា អំពីផែនការសម្រាប់ធ្វើវីដេអូផ្សព្វផ្សាយច្បាប់ និងពិភាក្សាមេរៀនស្តីពី នីតិវិធីអនុវត្តដោយបង្ខំ នៅក្នុងសំណុំរឿងរដ្ឋប្បវេណី។

ការប្រជុំគណៈកម្មការកិច្ចការរដ្ឋប្បវេណីប្រចាំខែកក្កដា

នៅថ្ងៃអង្គារ ១២កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការរដ្ឋប្បវេណី នៃគណៈមេធាវី។ លទ្ធផលដែលទទួលបានគឺ គណៈកម្មការបានសម្រេចរៀបចំឲ្យមានបទបញ្ជាផ្ទៃក្នុងសម្រាប់គណៈកម្មការកិច្ចការរដ្ឋប្បវេណី និងរៀបចំផែនការសកម្មភាព សម្រាប់ផ្សព្វផ្សាយ តាមរយៈសិក្ខាសាលា វិទ្យុ ទូរទស្សន៍ និងព្រឹត្តិបត្រ ហើយគណៈកម្ម-ការកិច្ចការរដ្ឋប្បវេណី និងមានកិច្ចប្រជុំរៀងរាល់មួយខែម្តង។

៣.៥ កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ

កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ជាលើកទី២

នៅថ្ងៃអាទិត្យ ១៤រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិកគណៈកម្ម-ការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិជាលើកទី២ ក្រោមការដឹកនាំប្រជុំដោយលោកមេធាវី គង់ សំអុន ប្រធានគណៈកម្មការ។

នៅក្នុងកិច្ចប្រជុំ សមាជិក-សមាជិការគណៈកម្មការបានពិភាក្សាលើការកែសម្រួលបទបញ្ជាផ្ទៃក្នុង ផែនការសកម្មភាពការងារដែលទាក់ទងនឹងការធ្វើជាវាគ្មិន សម្រាប់សិក្ខាសាលាការបណ្តុះបណ្តាលមេធាវីចូលប្រកបតាមមាត្រា៣២ ការធ្វើជាវាគ្មិនក្នុងប៉ុស្តិ៍ទូរទស្សន៍បាយ័ន ការសរសេរអត្ថបទដាក់ចូលព្រឹត្តិបត្រគណៈមេធាវី ការវាយតម្លៃពីការយល់ដឹងរបស់សហភាតាអំពីសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ ការទៅទស្សនៈកិច្ចនៅក្រៅប្រទេស បញ្ហាការសរសេរសារណារបស់សហភាតានៅតុលាការកំពូល និងទាក់ទងការកំណត់ចំនួនសមាជិកចូលរួចសិក្ខាសាលា ។

.កិច្ចប្រជុំសមាជិកគណៈកម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិប្រចាំខែសីហា

នៅថ្ងៃសៅរ៍ ៨រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំសមាជិក-សមាជិកា គណៈកម្មការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ នៃគណៈមេធាវី។

លទ្ធផលដែលទទួលបាន គឺអង្គប្រជុំបានសម្រេចឲ្យសមាជិកធ្វើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង កំណត់ប្រធានបទសម្រាប់ធ្វើការស្រាវជ្រាវ និង បានរៀបចំផែនការសម្រាប់ផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងព្រឹត្តិបត្រ។ គណៈកម្មការនឹងជួបប្រជុំរៀងរាល់ពីរខែម្តង។

៤. ការផ្សព្វផ្សាយច្បាប់តាមរយៈ សិក្ខាសាលា ឬទូរទស្សន៍

៤.១ ការផ្សព្វផ្សាយច្បាប់តាមរយៈ សិក្ខាសាលា

លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីបានធ្វើបាឋកថាស្តីពី "ដំណើរការស្នាក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ" ជូនដល់សិក្ខាកាមបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី១០ នៅបណ្ឌិតសភានគរបាលកម្ពុជា

នៅថ្ងៃច័ន្ទ ១០រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០១៨ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីបានធ្វើបាឋកថាស្តីពី "ដំណើរការស្នាក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ" ជូនដល់សិក្ខាកាមបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី១០ នៅបណ្ឌិតសភានគរបាលកម្ពុជា។

សិក្ខាសាលាក្រោមប្រធានបទ "ការចូលរួមរបស់អ្នកអនុវត្តច្បាប់ និងស្ថាប័នហិរញ្ញវត្ថុក្នុងការប្រឆាំងការជួញដូរមនុស្ស"

នាថ្ងៃព្រហស្បតិ៍ ៥ កើត ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយអង្គការសេរី

ភាពអាស៊ី (Liberty Asia) និងអង្គការតម្លាភាពកម្ពុជា បានរៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពី "ការចូលរួមរបស់អ្នកអនុវត្តច្បាប់ និងស្ថាប័នហិរញ្ញវត្ថុក្នុងការប្រឆាំងការជួញដូរមនុស្ស" នៅសណ្ឋាគារសាន់វេ ក្រោមអធិបតីភាពលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការនៃគណៈមេធាវី។

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារៀបចំសិក្ខាសាលាស្តីពី "ការលក់ដោយបង្ខំចំពោះអចលនវត្ថុ"

ក្រោមកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា សហព័ន្ធគណៈមេធាវីជប៉ុន (JFBA) និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងយុត្តិធម៌ជប៉ុន (ICD) នៅថ្ងៃព្រហស្បតិ៍ ៤រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីបានរៀបចំសិក្ខាសាលាស្តីពី"ការលក់ដោយបង្ខំចំពោះអចលនវត្ថុ"

នៅក្នុងសិក្ខាសាលានេះក៏មានសាស្ត្រាចារ្យជាតិ និងអន្តរជាតិចូលរួមធ្វើបទបង្ហាញផងដែរ នៅក្នុងនោះរួមមានលោកមេធាវី អ៊ីវ ប៉ូលី ប្រធានគណៈកម្មការកិច្ចការរដ្ឋប្បវេណីនៃគណៈមេធាវី លោកមេធាវី SATO Naoshi សាស្ត្រាចារ្យ និងជាមេធាវីរបស់ FJBA លោកស្រីមេធាវី Ms. SUZUKI Ichiko សាស្ត្រាចារ្យ និង ជាចៅក្រមនៃ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

នៃក្រសួងយុត្តិធម៌ជប៉ុន (ICD) និងលោកមេធាវី YOSHIZAWA Tosghiyuki មេធាវី JFBA។

នៅរសៀលថ្ងៃនោះផងដែរ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី និងសហការីបានចូលរួមពិសារអាហារសាគ្គីជាមួយភាគីជប៉ុន ដើម្បីជជែកពីកិច្ចសហប្រតិបត្តិការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាមួយ និងសហព័ន្ធគណៈមេធាវីជប៉ុន (JFBA) និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិនៃ ក្រសួងយុត្តិធម៌ជប៉ុន (ICD) ។

សិក្ខាសាលាស្តីពី“ ការលក់ដោយបង្ខំចំពោះអចលនវត្ថុ”

៤.២ ការផ្សព្វផ្សាយច្បាប់តាមរយៈ ទូរទស្សន៍

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ លោកមេធាវី **កុយ គន្ធី** និងលោកមេធាវី **ពិន វណ្ណៈ** សមាជិកគណៈកម្មការច្បាប់ពាណិជ្ជកម្មនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចូលកម្មវិធីច្បាប់អំពី "ភតិសន្យាហិរញ្ញវត្ថុ" នៅស្ថានីយប៉ុស្តបាយ័ន BTV ។

សហភាតាអាចចូលមើលសកម្មភាពនៃការវាគ្មិនបានតាមរយៈ គេហទំព័រសង្គមផ្លូវការរបស់គណៈមេធាវី សូមចុចតំណភ្ជាប់ខាងក្រោម៖

https://web.facebook.com/BAKCCambodia/videos/2469573489781285/

៥.សេចក្តីជូនដំណឹង និងសេចក្តីសម្រេចផ្សេងៗក្នុងត្រីមាសទី៣

សេចក្តីជូនដំណឹងអំពីការទទួលយកប័ណ្ណសម្គាល់ខ្លួនមេធាវីប្រភេទថ្មីដែលមានសុពលភាព០៥ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឌិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ឧត្តរ
២-មេធាវី អ៊ីវ ភិរៃធា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៉ូលី
៥-មេធាវី ម៉ៀង សំបូ
៦-មេធាវី ជា សុភក្តិន
៧-មេធាវី សាន់ ជុយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជុ ចាន់ប៊ីរ
១០-មេធាវី កេត សុម៉ាឡា
១១-មេធាវី ម៉ុ ឌីណា
១២-មេធាវី សេង សុខយ៉ាម
១៣-មេធាវី លីម សុវណ្ណារា
១៤-មេធាវី ឈីម ភិរម្យ
១៥-មេធាវី សំ សុកន់
១៦-មេធាវី ឧត ហានតូ
១៧-មេធាវី អ៊ុ ឌីតារៅ
១៨-មេធាវី លី ពីធ
១៩-មេធាវី យ៉ាម ឌិសុត
២០-មេធាវី លីម ម៉ូលីកា
២១-មេធាវី កែ ឌិសាល
២២-មេធាវី ហ្ស លីហ្ស
២៣-មេធាវី ង៉ា ពិសី
២៤-មេធាវី ជា ហុតវ៉ា
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ឌីមានចំណា
២៧-មេធាវី ឈី សម្ផ្ការ

លេខ ២៣២៧ /គម/១៨

ថ្ងៃ ២៤ ៥ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៨

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
ជម្រាបជូន
សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ ÷ អញ្ជើញសមាជិក-សមាជិកាគណៈមេធាវីមកទទួលយកប័ណ្ណសម្គាល់ខ្លួនមេធាវី ។

តបតាមកម្មវត្ថុខាងលើ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបដល់សហភាពដែលជាមេធាវីពេញសិទ្ធិ និងមេធាវីសុំមិនប្រកបវិជ្ជាជីវៈ សូមអញ្ជើញមកយកប័ណ្ណសម្គាល់ខ្លួនមេធាវី នៅនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវី ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ នៅវ៉ៃងរាល់ម៉ោងធ្វើការ ។

ប័ណ្ណសម្គាល់ខ្លួនមេធាវីនេះ គឺប្រើប្រាស់សម្រាប់សម្គាល់ខ្លួនមេធាវីនៅតាមសាលាជម្រះក្តីនានា និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេស ប្រើប្រាស់សម្រាប់បោះឆ្នោតជ្រើសតាំងប្រធាន និងក្រុមប្រឹក្សាគណៈមេធាវីនាពេលខាងមុខនេះ ។ ប័ណ្ណសម្គាល់ខ្លួនមេធាវីថ្មីនេះមានសុពលភាពប្រាំ (០៥) ឆ្នាំ គិតចាប់ពីថ្ងៃចេញប័ណ្ណ និងចែកជូនសមាជិក-សមាជិកាគណៈមេធាវីដោយឥតគិតថ្លៃ ។ ប៉ុន្តែ នៅក្នុងរយៈពេលសុពលភាពនេះ ប្រសិនបើប័ណ្ណសម្គាល់ខ្លួនមេធាវីបាត់ ឬខូច សាមីមេធាវីតម្រូវឱ្យបង់ប្រាក់ USD ១០ (ដប់ដុល្លារអាមេរិក) សម្រាប់ការផលិតប័ណ្ណសម្គាល់ខ្លួនមេធាវីថ្មីឡើងវិញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជ្រាប និងចាត់ចែងមកទទួលយកប័ណ្ណសម្គាល់ខ្លួនតាមការគួរ ។

សូមសមាជិក-សមាជិកាគណៈមេធាវី ទទួលនូវការគោរពដ៏អស្ចារ្យ អំពីខ្ញុំ ។

ប្រធាន

មេធាវី សួន ឌិសាល

អាគារស្ថិតនៅកាត់ប្រសព្វផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ, ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.kh

លិខិតអញ្ជើញសមាជិក-សមាជិកាគណៈមេធាវីចូលរួមមហាសន្និបាតលើកទី ២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ទិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាន ឫទ្ធិ
២-មេធាវី អ៊ីង ភារ៉ៃយ
៣-មេធាវី កែត លី
៤-មេធាវី អ៊ីម ចុំលី
៥-មេធាវី ឡៅ លំដូ
៦-មេធាវី ជា សុភក្តិ
៧-មេធាវី សាន់ ជុយ
៨-មេធាវី ជាន ជាតិត
៩-មេធាវី ជុ ចាន់ធីតា
១០-មេធាវី គេង សុម៉ាលា
១១-មេធាវី ម៉ី ឌីសតា
១២-មេធាវី សេង សុខឆាយ
១៣-មេធាវី លីម សុវណ្ណារា
១៤-មេធាវី ឈឹម ភីរម្យ
១៥-មេធាវី សំ សុកាន់
១៦-មេធាវី ឌុង ហានឌួ
១៧-មេធាវី ហ៊ូ ធីតារេវ
១៨-មេធាវី លី ណីត
១៩-មេធាវី យ៉ាម ទិសិរុត
២០-មេធាវី លឹម ម៉ូណូលីសា
២១-មេធាវី កែ ទិសាល
២២-មេធាវី ហ្ស លីហ្ស
២៣-មេធាវី ម៉ា ណិលី
២៤-មេធាវី ជា ហុកហ៊ី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ទិមានម៉ាលី
២៧-មេធាវី ឈី សម្ប្ញតិ

លេខ២១២៤ /គម/១៨

ថ្ងៃសុក្រ ១០កើត ខែស្រាពណ៍ ឆ្នាំច ស័ក្ត្រិ ១.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៨

សូមជម្រាបជូន

សមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ ÷ អញ្ជើញសមាជិក-សមាជិកាគណៈមេធាវីចូលរួមមហាសន្និបាតលើកទី ២៣ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

យោង ÷ -ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
-បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី
-ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមអញ្ជើញសមាជិក-សមាជិកាគណៈមេធាវីចូលរួមមហាសន្និបាតលើកទី ២៣ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី១៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ០៧ : ៣០ នាទីព្រឹក នៅសណ្ឋាគារ រ៉ូស៊ីដង់ សុខាភ្នំពេញ ផ្លូវកែវចិន្តា ភូមិទី១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ។ នៅក្នុងមហាសន្និបាតលើកទី ២៣ នេះដែរ នឹងមានរៀបចំបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីអាណត្តិទី ១២ (២០១៨-២០២០) និងបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ០៩ (២០១៨-២០២១) ផងដែរ ។

អាស្រ័យហេតុនេះ សូមសមាជិក-សមាជិកាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួម កុំបីអាក់ខាន ។

សូមសមាជិក-សមាជិកាគណៈមេធាវី មេត្តាយកចិត្តទុកដាក់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ប្រ ធា ន

ជូនភ្ជាប់ៈ កម្មវិធីមហាសន្និបាត
សម្បៀតបំពាក់ៈ អាវិជ្ជាជីវៈមេធាវី

មេធាវី. សួន_ទិសាល

អគារស្ថិតនៅកាត់ក្រុមផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.kh

សេចក្ដីជូនដំណឹងស្ដីពីការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

លេខ ២០ ៥២ /គម/១៨

ថ្ងៃ ៥ រោច ២ កើត ៩ ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
ជម្រាបជូន
សមាជិក-សមាជិកានៃគណៈមេធាវី

កម្មវត្ថុ ÷ ការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ០៩ ។
យោង ÷-ច្បាប់ស្ដីពីលក្ខន្ដិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
-ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនសមាជិក-សមាជិកា ដែលជាមេធាវីពេញសិទ្ធិទាំងអស់ជ្រាបថា គណៈមេធាវីនឹងរៀបចំធ្វើការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ០៩ (២០១៨-២០២១) នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ខាងមុខនេះ។ គណៈមេធាវីចាប់ផ្ដើមទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាគណៈមេធាវី **ចាប់ពីថ្ងៃជូនដំណឹងនេះ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១៨ វេលាម៉ោង ៥ : ០០ រសៀល នៅទីស្នាក់ការគណៈមេធាវី** ។

លក្ខខណ្ឌឈរឈ្មោះ ៖
- ជាមេធាវីពេញសិទ្ធិ ចាប់ពី ២ (ពីរ) ឆ្នាំ ឡើងទៅ
- ជាមេធាវីមានសិទ្ធិបោះឆ្នោត និង
- ឥតដែលបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយ ។

អាស្រ័យហេតុនេះ សមាជិក-សមាជិកាមេធាវីដែលមានបំណងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ០៩ អាចអញ្ជើញមកដាក់ពាក្យ នៅទីស្នាក់ការគណៈមេធាវី នៅម្រៀងរាល់ម៉ោងធ្វើការ ឱ្យបានមុនកាលបរិច្ឆេទឈប់ទទួលពាក្យដូចបានរៀបរាប់ខាងលើ។ សូមភ្ជាប់មកជាមួយនូវពាក្យស្នើសុំ រូបថត (ពាក់អាវរ៉ូបមេធាវី ថតថ្មី) ម៉ាត់ ៤×៦ ចំនួន ១ (មួយ) សន្លឹក ។

សូម សមាជិក-សមាជិកាទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ចម្លងជូន :
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
-ឯកសារ-កាលប្បវត្តិ

មេធាវី. សួន-ឥសាលី

ប្រធានគណៈមេធាវី
មេធាវី សួន ឥសាលី
ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង ចណ្ណៈ
២-មេធាវី អ៊ីង ភារ៉ា
៣-មេធាវី កែវ យី
៤-មេធាវី អ៊ីង ប៊ូលី
៥-មេធាវី ម៉ៀង សំបូ
៦-មេធាវី ជា សុកខូន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ជាន ជានិត
៩-មេធាវី ជូ ចាន់ធីតា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឌីសតា
១២-មេធាវី សេង សុខយ៉ាម
១៣-មេធាវី លីម សុវណ្ណារ
១៤-មេធាវី លីម ភារ៉ារ
១៥-មេធាវី សំ សុភាន់
១៦-មេធាវី ឌុង ហានឌូ
១៧-មេធាវី ម៉ូ ចីតារ៉ា
១៨-មេធាវី លី ពីន
១៩-មេធាវី យ៉ីម ឥសូត
២០-មេធាវី លីម ម៉ូនលីដា
២១-មេធាវី កែ ឥសាលី
២២-មេធាវី ឃុ លីឃុន
២៣-មេធាវី ម៉ា ពិសី
២៤-មេធាវី ជា ឃុនរ៉ា
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ឥសាឌម៉ា
២៧-មេធាវី លី សម្បត្តិ

អគារស្ថិតនៅកាច់ក្រោងផ្លូវលេខ ១១២៥ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1125 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.kh

សេចក្ដីជូនដំណឹងស្ដីពី ការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនប្រធានគណៈមេធាវី អាណត្តិទី១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឌិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ឧត្តម
២-មេធាវី អ៊ីង ភិរិយា
៣-មេធាវី កែត លី
៤-មេធាវី អ៊ីវ ប៊ុលី
៥-មេធាវី ម៉ៀង សំបូ
៦-មេធាវី ជា សុកខុន
៧-មេធាវី សាន់ ជុយ
៨-មេធាវី ជាន ជានិត
៩-មេធាវី ជុ ចាន់ធីណា
១០-មេធាវី កេង សុម៉ាលា
១១-មេធាវី ម៉ី ឌីសកា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុវណ្ណារា
១៤-មេធាវី លីម ភិរុយ
១៥-មេធាវី សំ សុកន់
១៦-មេធាវី ឌុង ហេងឌួ
១៧-មេធាវី ម៉ុ ចិត្តវៃ
១៨-មេធាវី លី ពីន
១៩-មេធាវី យីម ឌិស្សុត
២០-មេធាវី លីម ម៉ូនលីដា
២១-មេធាវី កែ ឌិសាល
២២-មេធាវី ហ្ស លីហ្ស
២៣-មេធាវី ម៉ា ណិលី
២៤-មេធាវី ជា ហុងរ៉ា
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ឌិមានម៉ា
២៧-មេធាវី លី សម្បត្តិ

លេខ ២០៥៣ /គម/១៨

ថ្ងៃ ២ កើត ខែស្រាពណ៍ ឆ្នាំច ស័ក្ដិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៨

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ជម្រាបជូន

សមាជិក-សមាជិកានៃគណៈមេធាវី

កម្មវត្ថុ ÷ ការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនប្រធានគណៈមេធាវី អាណត្តិទី ១២ ។

យោង ÷-ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
-បទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
-ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនសមាជិក-សមាជិកា ដែលជាមេធាវីពេញសិទ្ធិទាំងអស់ជ្រាបថា គណៈមេធាវីនឹងរៀបចំធ្វើការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីអាណត្តិទី ១២ (២០១៨-២០២០) នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ខាងមុខនេះ ។ គណៈមេធាវីចាប់ផ្ដើមទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនប្រធានគណៈមេធាវី **<u>ចាប់ពីថ្ងៃជូនដំណឹងនេះ ដល់ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៨ វេលាម៉ោង ៥ : ០០ រសៀល នៅទីស្នាក់ការគណៈមេធាវី</u>** ។

លក្ខខណ្ឌឈរឈ្មោះ ÷

- ជាមេធាវីពេញសិទ្ធិ ចាប់ពី ៣ (បី) ឆ្នាំ ឡើងទៅ
- ជាមេធាវីមានសិទ្ធិបោះឆ្នោត និង
- ឥតដែលបាត់បង់សិទ្ធិបោះឆ្នោតដោយទណ្ឌកម្មវិន័យណាមួយ ។

អាស្រ័យហេតុនេះ សមាជិក-សមាជិកាមេធាវីដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធានគណៈមេធាវី អាណត្តិទី ១២ អាចអញ្ជើញមកដាក់ពាក្យ នៅទីស្នាក់ការគណៈមេធាវី នៅរៀងរាល់ម៉ោងធ្វើការ ឱ្យបានមុនកាលបរិច្ឆេទឈប់ទទួលពាក្យដូចបានរៀបរាប់ខាងលើ ។ សូមភ្ជាប់មកជាមួយនូវពាក្យស្នើសុំ រូបថត (ពាក់អាវ៉ូបមេធាវី ថតថ្មី) ទំហំ ៤x៦ ចំនួន ១ (មួយ) សន្លឹក ។

សូម សមាជិក-សមាជិកាទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ ។

ចម្លងជូន :
-ឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍
-ក្រុមប្រឹក្សាគណៈមេធាវី
-ឯកសារ-កាលប្បវត្តិ

មេធាវី សួន ឌិសាល

អគារស្ថិតនៅកាន់ក្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧. ទូរស្ព: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.kh

សេចក្ដីជូនដំណឹង ស្ដីពីការផ្ដល់នូវអាសយដ្ឋាន លេខទូរស័ព្ទ សារអេឡេចត្រូនិច (Email) និងរូបថត សម្រាប់ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមេធាវីឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឫទ្ធី
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាន ឧត្តរ
២-មេធាវី ម៉ែន ភីរ៉ា
៣-មេធាវី កែត ធី
៤-មេធាវី ម៉ុន ម៉ូលី
៥-មេធាវី ម្ងៀត សំបូរ
៦-មេធាវី ជា សុភាព
៧-មេធាវី សាន ជុម
៨-មេធាវី ផាន ផានិត
៩-មេធាវី ជុ ចាន់ធីតា
១០-មេធាវី អេង សុម៉ាលា
១១-មេធាវី ម៉ី ឌីសារ
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុមន្ត្រា
១៤-មេធាវី លីម ភីរុយ
១៥-មេធាវី ស៊ ស្រីតន់
១៦-មេធាវី ឌុ ហាងឌួ
១៧-មេធាវី ម៉ូ ទីតារ៉ា
១៨-មេធាវី លី ណីត
១៩-មេធាវី យ៉ីម ទិសុត
២០-មេធាវី លីម ម៉ូលីកា
២១-មេធាវី កែ ទិសាណ
២២-មេធាវី ហ្ស លីហុង
២៣-មេធាវី ម៉ា ភិសី
២៤-មេធាវី ជា ហុងហ
២៥-មេធាវី សៅ ភញ្ញា
២៦-មេធាវី ម៉ុន ទិមាន់ចិត
២៧-មេធាវី យ៉ី សម្ប្ញិ

លេខ ០០០១ /គម.សជណ/១៨

ថ្ងៃ អង្គារ ១១ រោច ខែទុតិយាសាឍ ឆ្នាំច ស័ក្ដិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៨

សេចក្ដីជូនដំណឹង

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដំណឹងដល់សមាជិក-សមាជិកា គណៈមេធាវីទាំងអស់ជ្រាបថា គណៈមេធាវីកំពុងធ្វើបច្ចុប្បន្នភាពស្បៀវភៅបញ្ជីឈ្មោះមេធាវី ដើម្បីរៀបចំបោះពុម្ពសម្រាប់ឆ្នាំ២០១៨ នេះ។

ដូចនេះ សូមសមាជិក-សមាជិកាគណៈមេធាវីមេត្តាផ្ដល់ទូវអាសយដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ សារអេឡិចត្រូនិច (Email) និងរូបថតបច្ចុប្បន្នភាព មកនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវី ឱ្យបានមុនថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨។ ក្នុងករណីយឺតយ៉ាវ គណៈមេធាវីមិនទទួលខុសត្រូវឡើយ។

សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកលេខទូរស័ព្ទ៖ ០៩៦ ២៥ ០២៦ ២២ / ០១៧ ៨៤២ ៩១១ / ០៧៦ ២៥ ១៦៨ ២៥ ។

អគារស៊ីតណាក់ក្ដាប់ផ្ទាំលេខ ១១២៨ និងផ្ទាំលេខ ១៤៣០ សង្កាត់ភ្ជុំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ១១៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៦២២ ៧០៧០
E-mail: info@bakc.org.kh, website: www.bakc.org.kh

សូមជូនដំណឹងអំពីសេចក្តីសម្រេចស្តីពី ការប្រគល់-ទទួលសិទ្ធិសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីអាណត្តិទី១២ (២០១៨-២០២០) និងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៩ (២០១៨-២០២១)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ឌីសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាន ឌណ្ណៈ
២-មេធាវី អ៊ុង ភិរោ
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីង ប៉ូលី
៥-មេធាវី ឈៀ សំបូ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជុយ
៨-មេធាវី ជាន ជានិត
៩-មេធាវី ជុ ចាន់ធីតា
១០-មេធាវី អេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខយ៉ាម
១៣-មេធាវី លីម សុខណ្ណា
១៤-មេធាវី ឈីង ភីរម្យ
១៥-មេធាវី សំ សុកន់
១៦-មេធាវី នង ហានឌូ
១៧-មេធាវី ម៉ូ ម៉ីការ៉ា
១៨-មេធាវី លី ហ៊ីង
១៩-មេធាវី យ៉ីម ឌីសុត
២០-មេធាវី លីម ម៉ាលីកា
២១-មេធាវី ង៉ែ ឌីសាល
២២-មេធាវី ហ្ស លីហ្ស
២៣-មេធាវី ម៉ា ណារី
២៤-មេធាវី ជា ហុងរ៉ា
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ឌីហានម៉ា
២៧-មេធាវី ឈី សម្ផត្តិ

លេខ ២២ /សសគម/១៨

ថ្ងៃសុក្រ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៨

សេចក្តីសម្រេច
ស្តីពី
ការប្រគល់-ទទួលសិទ្ធិ
សម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី ១២ (២០១៨-២០២០)
និងការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៩ (២០១៨-២០២១)

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញាឆ្នាំ ២០១២
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៨
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ឌីសាល** ជាប្រធានគណៈមេធាវី អាណត្តិទី ១១
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ។

អគារស្ថិតនៅកាច់ក្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧. ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Str and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bak

ស ម្រេ ច

ប្រការ ១. លិខិតប្រគល់-ទទួលសិទ្ធិត្រូវមានហត្ថលេខា និងប្រថាប់ត្រាមេធាវី-ត្រាឈ្មោះ ឬឈ្មោះសរសេរដោយដៃរបស់មេធាវីប្រគល់សិទ្ធិ និងមេធាវីទទួលសិទ្ធិ។

ប្រការ ២. ហាមសមាជិក-សមាជិកាគណៈមេធាវី ដែលមានសិទ្ធិបោះឆ្នោតផ្ទេរសិទ្ធិបោះឆ្នោតរបស់ខ្លួន សម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីជូនសហភាពមេធាវីលើសពីម្នាក់ ឬធ្វើការផ្ទេរសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវីជូនសហភាពមេធាវីលើសពីម្នាក់។

ប្រការ ៣. ក្នុងករណីបំពានប្រការ ២ ខាងលើ លិខិតប្រគល់-ទទួលសិទ្ធិទាំងនោះត្រូវទុកជាមោឃៈ ហើយសហភាពមេធាវី ដែលជាអ្នកប្រគល់សិទ្ធិជូនសហភាពលើសពីម្នាក់ត្រូវរងទណ្ឌកម្ម ដោយដកសិទ្ធិមិនឱ្យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោតនោះ ព្រមទាំងត្រូវរងទណ្ឌកម្មវិន័យផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ប្រការ ៤. លិខិតប្រគល់-ទទួលសិទ្ធិច្បាប់ដើមត្រូវប្រគល់ជូនគណៈកម្មការរៀបចំការបោះឆ្នោតឱ្យបានមុនពេល ដែលគណៈកម្មការរៀបចំការបោះឆ្នោតចាប់ផ្តើមនីតិវិធីប្រកាសអំពីការប្រគល់-ទទួលសិទ្ធិក្នុងពេលមហាសន្និបាតបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី និងបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាគណៈមេធាវី ឬអាចប្រគល់ឱ្យគណៈមេធាវីឱ្យបានមុនថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៨ ដើម្បីសម្រួលការងារដល់គណៈកម្មការរៀបចំការបោះឆ្នោតក្នុងការបូកសរុប និងរាយការណ៍ជូនមហាសន្និបាត។

ប្រការ ៥. រាល់ការប្រគល់-ទទួលសិទ្ធិតាមរយៈទូរសារ សារអេឡិចត្រូនិច (E-mail) ឬលិខិតថតចម្លង ឬពុំបានធ្វើឡើងតាមទម្រង់ និងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១ ខាងលើនោះចាត់ទុកថាពុំមានសុពលភាព និងពុំអាចអនុញ្ញាតឱ្យបោះឆ្នោតជំនួសបានឡើយ។ លិខិតប្រគល់-ទទួលសិទ្ធិមួយអាចប្រើបានតែក្នុងសម័យបោះឆ្នោតម្តងប៉ុណ្ណោះ។

ប្រការ ៦. រាល់ការលុបចោលនូវការយល់ព្រមប្រគល់សិទ្ធិ ឬទទួលសិទ្ធិអាចធ្វើឡើងបានដោយមេធាវីប្រគល់សិទ្ធិ ឬមេធាវីទទួលសិទ្ធិ។ ការលុបចោលនេះត្រូវជូនដំណឹងភ្លាមទៅគណៈកម្មការរៀបចំការបោះឆ្នោត ដោយធ្វើយ៉ាងណាឱ្យបានមុនពេល ដែលគណៈកម្មការរៀបចំការបោះឆ្នោតចាប់ផ្តើមនីតិវិធីប្រកាស អំពីការប្រគល់-ទទួលសិទ្ធិក្នុងពេលមហាសន្និបាត នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ហើយត្រូវប្រកាសជាសាធារណៈក្នុងពេលមហាសន្និបាត។

ប្រការ ៧. គណៈកម្មការរៀបចំការបោះឆ្នោតត្រូវចារលើលិខិតប្រគល់សិទ្ធិដែលស្នើសុំលុបចោលដោយមេធាវីទទួលសិទ្ធិ ឬមេធាវីប្រគល់សិទ្ធិ និងបញ្ជាក់ថាទុកជាមោឃៈ ។

ប្រការ ៨. បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្ជីមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩. គណៈកម្មការរៀបចំការបោះឆ្នោត អគ្គលេខាធិការគណៈមេធាវី បេក្ខជនប្រធានបេក្ខជនក្រុមប្រឹក្សាគណៈមេធាវី និងសមាជិក-សមាជិកាគណៈមេធាវីទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រ ធា ន

ចម្លងជូន.
-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
"ដើម្បីជូនជ្រាប"
-ក្រុមប្រឹក្សាគណៈមេធាវី
-ដូចប្រការ ៩
-ឯកសារ-កាលប្បវត្តិ

មេធាវី សុន_ វិសាល

សូមជូនដំណឹងអំពីសេចក្តីសម្រេចស្តីពីការទទួលស្គាល់បេក្ខជនឈរឈ្មោះ

សូមជូនដំណឹងអំពីសេចក្តីសម្រេចស្តីពី ការទទួលស្គាល់បេក្ខជនឈរឈ្មោះប្រធានគណៈមេធាវី អាណត្តិទី១២ (២០១៨-២០២០) និង បេក្ខជនឈរឈ្មោះក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩ (២០១៨-២០២១) និងការជូនដំណឹងអំពីសេចក្តីសម្រេចស្តីពីការយោសនាបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី សួន វិសាល

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង ឧត្តរៈ
២-មេធាវី អ៊ុច គីមិយា
៣-មេធាវី កែត យី
៤-មេធាវី អ៊ុង ប៊ុលី
៥-មេធាវី ទៀង សំបុរ
៦-មេធាវី ជា សុគន្ធ
៧-មេធាវី សាត់ ជួយ
៨-មេធាវី ថាន ថាវិត
៩-មេធាវី ជូ ចាន់ពីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ធនសា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុខណ្ណា
១៤-មេធាវី ឈឹម តិអៀ
១៥-មេធាវី សំ សុគង់
១៦-មេធាវី ឆន មាឌូ
១៧-មេធាវី អ៊ុ ចិតាពៅ
១៨-មេធាវី លី កិច
១៩-មេធាវី យឹម វិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កៃ វិសាល
២២-មេធាវី ហូ លីហុង
២៣-មេធាវី ចំ គិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុង មិអាលចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ ២៧៧២១ /គម/១៨

ថ្ងៃ សុក្រ ៥កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៨

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ជម្រាបជូន

សមាជិក-សមាជិកាគណៈមេធាវី

កម្មវត្ថុ ៖ ការជូនឈ្មោះបេក្ខជនឈរឈ្មោះជាប្រធានគណៈមេធាវី អាណត្តិទី១២ (២០១៨-២០២០) និងបេក្ខជនឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៩ (២០១៨-២០២១) ។

យោង ៖ - ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី

- បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី
- លិខិតលេខ ២០៥២/គម/១៨ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់គណៈមេធាវី
- លិខិតលេខ ២០៥៣/គម/១៨ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់គណៈមេធាវី
- សេចក្ដីសម្រេចរបស់គណៈមេធាវី លេខ ៥៥១/សសគម/១៨ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនសមាជិក-សមាជិកាគណៈមេធាវីទាំងអស់ជ្រាបថា កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ក្រុមប្រឹក្សាគណៈមេធាវីបានពិនិត្យ និងសម្រេចជាផ្លូវការលើលក្ខណៈសម្បត្តិរបស់បេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវី អាណត្តិទី១២ (២០១៨-២០២០) និងបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី៩ (២០១៨-២០២១) ហើយបានសម្រេចទទួលស្គាល់បេក្ខជនប្រធានគណៈមេធាវី ចំនួន ២ (ពីរ) រូបគឺ៖

១-លោកមេធាវី សួន វិសាល អត្តលេខ ១៤៣

២-លោកមេធាវី សំ សុគង់ អត្តលេខ ៣២១

និងបេក្ខជនសមាជិកក្រុមប្រឹក្សាគណៈមេធាវីចំនួន **១៥៨ (មួយរយហាសិបប្រាំបី)រូប** *(ដូចមានសេចក្ដីសម្រេចជូនភ្ជាប់មកជាមួយនេះ)*។

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧. ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 112 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.org.k

អាស្រ័យហេតុនេះ សូមសមាជិក-សមាជិកាគណៈមេធាវីជ្រាបជាព័ត៌មានតាមការគួរ ។
សូម សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្ររអំពីខ្ញុំ ។

ប្រ ធា ន

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី សួន-ឌិសាល

ចម្លងជូន៖

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន ទិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាន ចណ្ណៈ
២-មេធាវី អ៊ីន ភារ៉ៃយ
៣-មេធាវី កែត យី
៤-មេធាវី អ៊ីម ចុំលី
៥-មេធាវី ម៉ៀម សំបូ
៦-មេធាវី ជា សុកនុន
៧-មេធាវី សាន់ ជុយ
៨-មេធាវី ជាន ជានីត
៩-មេធាវី ជុ ចាន់ម៉ីង
១០-មេធាវី កេង សុម៉ាឌូ
១១-មេធាវី ម៉ី ឌីសតា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុខណារ
១៤-មេធាវី លីម ភីរយ
១៥-មេធាវី សំ សុកន់
១៦-មេធាវី ឌុង ឆានធូ
១៧-មេធាវី ប៊ុ ម៉ីតារៅ
១៨-មេធាវី លី ពីន
១៩-មេធាវី យីម ទិសុត
២០-មេធាវី លីម ម៉ូលីកា
២១-មេធាវី ង៉ែ ទិសាល
២២-មេធាវី ហ៊ុ លីហុង
២៣-មេធាវី ម៉ា ពិសី
២៤-មេធាវី ជា ហុងវ៉ា
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ទិមាតម៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ ៥៥១ /សសគម/១៨

ថ្ងៃ សុក្រ ៥ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៨

សេចក្តីសម្រេច
ស្តីពី
ការទទួលស្គាល់បេក្ខជនឈរឈ្មោះប្រធានគណៈមេធាវី អាណត្តិទី ១២ (២០១៨-២០២០) បេក្ខជនឈរឈ្មោះក្រុមប្រឹក្សាគណៈមេធាវី អាណត្តិទី ៩ (២០១៨-២០២១)

ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន ទិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១១
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ។

អគារស្ថិតនៅកាន់ប្រជុំផ្លូវលេខ ១១២៨ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០ ៧០ ,Building at Corner of Street 1 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box: 1587, Tel. 023 622 70 70 E-mail: info@bakc.org.kh / Website: www.bakc.or

អាស្រ័យហេតុនេះ សូមសមាជិក-សមាជិកាគណៈមេធាវីជ្រាបជាព័ត៌មានតាមការគួរ ។
